# ធ្មេញ អញ្ចាញធ្មេញ និងមាត់

ជំពូកទី ១៧

## ការថែទាំធ្មេញ និងអញ្ចាញធ្មេញ

ការថែទាំដោយយកចិត្តទុកដាក់ចំពោះធ្មេញ និងអញ្ចាញធ្មេញ មានសារសំខាន់ណាស់ ពីព្រោះ ៖

- ការមានធ្មេញដែលមានសុខភាពល្អនិងរឹងមាំ គឺជាតម្រូវការដើម្បីទំពារនិងបំបែកអាហារឲ្យបានល្អ។
- ធ្មេញដែលមានប្រហោង ហើយឈឺចាប់ (ប្រហោងក្នុងធ្មេញដែលបណ្ដាលមកពីធ្មេញពុក) និងដំបៅអញ្ចាញធ្មេញ អាចបង្ការបានដោយការថែទាំធ្មេញដ៏ល្អ។
- ធ្មេញពុកដោយសារខ្វះការសម្អាត អាចបណ្ដាលឲ្យមានការបង្ករោគធ្ងន់ធ្ងរ ដែលអាចប៉ះពាល់ដល់ផ្នែកដទៃទៀតនៃរាងកាយ។

*ដើម្បីថែរក្សាធ្មេញ និងអញ្ចាញធ្មេញឲ្យមានសុខភាពល្អ ៖*



*កុមារនេះមានធ្មេញផ្អែម ប៉ុន្តែ គាត់នឹងលែងមាន ទៀត ក្នុងរយៈពេលដ៏ខ្លី (អស់ធ្មេញ)។*

១. **ជៀសវាងបរិភោគជាតិស្ករ។** ការបរិភោគជាតិផ្អែមច្រើនពេក (ស្ករគ្រាប់ អំពៅ នំធ្វើពីម្សៅ តែឬកាហ្វេដាក់ស្ករ ភេសជ្ជៈផ្អែមដូចជាកូកាកូឡា) ធ្វើឲ្យធ្មេញឆាប់ពុក។

**កុំទម្លាប់កូនរបស់អ្នក ឲ្យបរិភោគស្ករគ្រាប់ ឬភេសជ្ជៈផ្អែម ប្រសិនបើអ្នកចង់ឲ្យពួកគេមានធ្មេញល្អ។**

២. **ដុសធ្មេញឲ្យបានត្រឹមត្រូវជារៀងរាល់ថ្ងៃ** ហើយត្រូវដុសធ្មេញភ្លាមៗបន្ទាប់ពីបានបរិភោគអាហារផ្អែម។ ចាប់ផ្ដើមដុសធ្មេញឲ្យកូនរបស់អ្នក នៅពេលពួកគេចាប់ផ្ដើមដុះធ្មេញ។ ក្រោយមក ត្រូវបង្រៀនពួកគេឲ្យដុសធ្មេញដោយខ្លួនឯង ហើយត្រូវពិនិត្យមើលថាតើពួកគេដុសបានត្រឹមត្រូវឬទេ។

៣. នៅតំបន់ណាដែលគ្មានជាតិហ្លួយអ័រ (Fluoride)ធម្មជាតិគ្រប់គ្រាន់ នៅក្នុងទឹកនិងអាហារ ការដាក់ជាតិហ្លួយអ័រទៅក្នុងទឹកផឹក ឬដាក់លើធ្មេញផ្ទាល់តែម្ដង អាចជួយបង្ការការពុកធ្មេញ។



*ដុសធ្មេញពីលើចុះក្រោមដូចនេះ*

*មិនមែនត្រឹមតែដុសពីម្ខាងទៅម្ខាងទៀតទេ*

*ដុសពីខាងមុខ ខាងក្រោយ ខាងលើ និងខាងក្រោម នៃធ្មេញទាំងអស់។*

កម្មវិធីសុខភាពខ្លះ បានដាក់ជាតិហ្លួយអ័រ លើធ្មេញរបស់កុមារ ១ឬ២ដងក្នុងមួយឆ្នាំ។ ម្យ៉ាងទៀត អាហារសមុទ្រស្ទើរតែទាំងអស់ មានបរិមាណជាតិហ្លួយអ័រយ៉ាងច្រើន។

*ប្រយត្ន័ ៖* ហ្លួយអ័រ អាចបំពុលយើងបាន ប្រសិនបើលេបវាច្រើនពេក។ ប្រើវាដោយប្រុងប្រយត្ន័ ហើយត្រូវទុកដាក់វាឲ្យផុតពីដៃកុមារ។ មុននឹងបន្ថែមហ្លួយអ័រទៅក្នុងទឹកផឹក ត្រូវធ្វើការវិភាគទឹកនោះ ដើម្បីឲ្យដឹងជាមុនសិន ថាតើវាត្រូវការបរិមាណហ្លួយអ័រប៉ុន្មាន។

៤. មិនត្រូវបំបៅកូនធំៗដោយប្រើដបបៅទេ។ ការជញ្ជក់ដបបៅយូរ ធ្វើឲ្យធ្មេញរបស់កុមារជាប់ជាតិស្ករ ហើយបណ្តាលឲ្យធ្មេញឆាប់ពុក។ (ជាការប្រសើរបំផុត គឺមិនត្រូវបំបៅកូនដោយប្រើដបបៅទេ។ មើលទំ.២៧១)

## មិនចាំបាច់ត្រូវតែមានច្រាសដុសធ្មេញទេ

អ្នកអាចប្រើមែកឈើតូចៗ ដូចនេះ

សម្រួចចុងមួយនេះ សម្រាប់សម្អាតចន្លោះធ្មេញ

ខាំចុងម្ខាងនេះឲ្យបែកៗ ហើយប្រើសរសៃទាំងនេះ ជាច្រាស



ឬរុំកន្សែងពោះគោគ្រើមៗជុំវិញចុងកំណាត់ឈើមួយ
ឬរុំវាជុំវិញម្រាមដៃរបស់អ្នក ហើយប្រើវាជាច្រាសដុសធ្មេញ



*កន្សែងពោះគោគ្រើមៗមួយផ្ទាំង*

## មិនចាំបាច់ត្រូវតែមានថ្នាំដុសធ្មេញទេ

ប្រសិនបើអ្នកដុសធ្មេញបានល្អ មានត្រឹមតែទឹក ក៏គ្រប់គ្រាន់ដែរ។ ការដុសលាងធ្មេញនិងអញ្ចាញដោយសម្ភារទន់ៗ ប៉ុន្តែគ្រើមៗបន្តិច គឺជាការសម្អាតធ្មេញដ៏ល្អមួយ។ មនុស្សមួយចំនួន សម្អាតធ្មេញរបស់គេដោយប្រើកំទេចធ្យូង ឬ អំបិល។ ឬអ្នកអាចធ្វើម្សៅដុសធ្មេញ ដោយលាយអំបិលជាមួយប៊ីកាបូណាតសូដា ក្នុងបរិមាណស្មើគ្នា។ ដើម្បីធ្វើឲ្យវាស្អិត ជ្រលក់ច្រាសសិន មុននឹងដាក់ម្សៅនេះទៅលើច្រាស។




អំបិលនិងប៊ីកាបូណាតអាចជំនួសថ្នាំដុសធ្មេញបានយ៉ាងល្អប្រសើរក្នុងការសម្អាតធ្មេញ។ ប្រសិនបើអ្នកគ្មានប៊ីកាបូណាតសូដាទេ អ្នកអាចប្រើអំបិលតែម្តងក៏បាន។

## ប្រសិនបើធ្មេញមានប្រហោងរួចទៅហើយ (ប្រហោងបណ្តាលមកពីការពុកផុយ)



ដើម្បីបង្ការការឈឺធ្មេញ ឬការកើតជាអាប់សែ ត្រូវជៀសវាងការបរិភោគអាហារផ្អែម ហើយត្រូវដុសធ្មេញឲ្យបានស្អាតជានិច្ច បន្ទាប់ការបរិភោគអាហារ។

ប្រសិនបើអាច ទៅជួបគ្រូពេទ្យធ្មេញ។ បើអ្នកទៅរកពេទ្យទាន់ពេល គាត់អាចធ្វើការសម្អាតធ្មេញ និងប៉ះធ្មេញដែលមានប្រហោង ធ្វើឲ្យវាអាចប្រើបានជាច្រើនឆ្នាំទៀត។

**នៅពេលដែលមានធ្មេញពុកឬប្រហោង កុំរង់ចាំដល់ពេលវាឈឺខ្លាំង។**
**ត្រូវទៅឲ្យពេទ្យធ្មេញប៉ះវាភ្លាម។**

# ការឈឺធ្មេញ និងអាប់សែ

*ដើម្បីបន្ថយការឈឺចាប់ ៖*

- សម្អាតប្រហោងនៅធ្មេញ ដោយយកកំទេចកាក សំណល់អាហារចេញឲ្យអស់។ បន្ទាប់មក ខ្ពុរជម្រះមាត់ជាមួយទឹកអំបិលក្តៅឧណ្ហៗ។
- លេបថ្នាំបន្ថយការឈឺចាប់ ដូចជាថ្នាំអាស្ពីរីន(Aspirin)។
- បើការបង្ករោគក្នុងធ្មេញ កាន់តែធ្ងន់ធ្ងរ(ហើម មានខ្ទុះ ហើមកូនកណ្តុរ) ប្រើអង់ទីប៊ីយ៉ូទិក ៖ ប៉េនីស៊ីលីនគ្រាប់(ទំ.៣៥១) ឬថ្នាំស៊ុលហ្វូណាមីដ(ទំ.៣៥៨) ឬថ្នាំតេត្រាស៊ីគ្លីន (Tetracycline)គ្រាប់(សម្រាប់តែមនុស្សធំ ទំ.៣៥៦)។

ប្រសិនបើការឈឺចាប់ និងការហើម នៅតែគ្មានការធូរស្រាលទេ ឬវាឈឺឡើងវិញ គួរតែដកធ្មេញនោះចោល។

ព្យាបាលអាប់សែជាបន្ទាន់ មុនពេលការបង្ករោគ រាលដាលដល់ផ្នែកដទៃទៀតនៃរាងកាយ។



*ការឈឺធ្មេញកើតឡើងនៅពេលធ្មេញដែលពុកផុយ ក្លាយជាមានការបង្ករោគ។*

*អាប់សែកើតឡើងនៅពេលដែលការបង្ករោគរាលដាលដល់ចុងនៃឬសធ្មេញ ហើយបង្កើតបានជាថង់ខ្ទុះ។*

# ការបង្ករោគនៅអញ្ចាញធ្មេញ

ការរលាកអញ្ចាញធ្មេញ (ក្រហមនិងហើម) ដែលមានការឈឺចាប់ និងងាយហូរឈាម គឺបណ្តាលមកពី ៖

១. មិនបានសម្អាតធ្មេញនិងអញ្ចាញធ្មេញឲ្យបានស្អាតល្អ ឬមិនបានញឹកញាប់គ្រប់គ្រាន់។

២. មិនបានបរិភោគអាហារូបត្ថម្ភឲ្យបានគ្រប់គ្រាន់ (កង្វះអាហារូបត្ថម្ភ)។



*ការបង្ការ និងការព្យាបាល ៖*

- ដុសធ្មេញឲ្យបានស្អាតល្អបន្ទាប់ពីបរិភោគអាហារ ដោយយកកាកសំណល់ដែលនៅជាប់ចន្លោះធ្មេញចេញឲ្យអស់។ ម៉្យាងទៀត បើអាច ដុសចេញឲ្យអស់នូវកំណកលឿងៗដែលនៅជាប់តាមជើងធ្មេញ។ **ការសម្អាតយ៉ាងទៀង ទាត់នៅខាងក្រោមអញ្ចាញធ្មេញ** ដោយប្រើអំបោះទាញនៅចន្លោះធ្មេញ ក៏អាចជួយបានដែរ។ ដំបូងការធ្វើរបៀប នេះបណ្តាលឲ្យមានការហូរឈាមយ៉ាងច្រើន ប៉ុន្តែក្រោយមក អញ្ចាញធ្មេញនឹងមានសុខភាពល្អ និងមិនសូវហូរ ឈាមទៀតទេ។
- បរិភោគអាហារការពារដែលសំបូរវិតាមីន ជាពិសេសដូចជា ស៊ុត សាច់ សណ្តែក បន្លែពណ៌បៃតងចាស់ និងផ្លែឈើ ដូចជាផ្លែក្រូច ក្រូចឆ្មា និងប៉េងប៉ោះ(មើលជំពូក១១)។ ជៀសវាងអាហារផ្អែម ស្អិត និងមានសរសៃច្រើន ដែលនាំឲ្យជាប់តាមចន្លោះធ្មេញ។

**ចំណាំ ៖** ជួនកាលថ្នាំប្រឆាំងការប្រកាច់ (ជំងឺឆ្កួតជ្រូក) ដូចជាថ្នាំហ្វេនីតូអ៊ីន(Phenytoin) បណ្តាលឲ្យហើមអញ្ចាញធ្មេញ និងធ្វើឲ្យអញ្ចាញធ្មេញលូតលាស់មិនល្អ(ទំ.៣៩០)។ បើមានបញ្ហានេះកើតឡើង ពិគ្រោះ ជាមួយភ្នាក់ងារសុខាភិបាល និងគិតអំពីការប្រើថ្នាំផ្សេងជំនួសវិញ។

# ដំបៅ ឬប្រេះនៅរង្វះមាត់



ដំបៅតូចៗនៅរង្វះមាត់របស់កុមារ គឺជារោគសញ្ញានៃកង្វះអាហារូបត្ថម្ភ។

កុមារដែលមានដំបៅរង្វះមាត់ គួរបរិភោគអាហារដែលសំបូរវីតាមីន និងប្រូតេអ៊ីន ដូចជាទឹកដោះគោ សាច់ត្រី សាច់ ស៊ុត សណ្តែកដី បន្លែបៃតង ផ្លែឈើ។

# ផ្ទាំងសៗ ឬពងតូចៗនៅក្នុងមាត់



**អណ្តាតត្រូវបានគ្របដណ្តប់ដោយ "ស្រទាប់" ពណ៌ស។** មានជំងឺជាច្រើនបណ្តាលឲ្យមានស្រទាប់ពណ៌ស ឬលឿងនៅលើអណ្តាត និងក្រអូមមាត់។ បញ្ហានេះកើតឡើងជាញឹកញាប់នៅពេលដែលមានគ្រុនក្តៅ។ ទោះបីជាស្រទាប់នេះគ្មានសភាពធ្ងន់ធ្ងរក៏ដោយ ក៏គួរតែខ្ពុរមាត់ជាមួយទឹកអំបិលក្តៅឧណ្ហៗ លាយជាមួយសូដាប៊ីកាបូណាត ឲ្យបានច្រើនដងក្នុងមួយថ្ងៃ។

កុមារដែលមានគ្រុនក្តៅ ហើយមាន**ពងពណ៌សតូចៗដូចគ្រាប់អំបិលនៅក្នុងមាត់** អាចជារោគសញ្ញាដំបូងនៃជំងឺកញ្ជ្រឹល( ទំ.៣១១ )។



**ជ្រាំង ៖** ផ្ទាំងពណ៌សតូចៗនៅក្នុងមាត់ និងលើអណ្តាត ដែលមើលទៅដូចជាផ្ទាំងកំណកទឹកដោះគោ ជាប់នៅលើសាច់។ វាកើតឡើងដោយសារមេរោគផ្សិត ឬការបង្ករោគដោយមេរោគផ្សិត ដែលគេហៅថា ម៉ូនីលីយ៉ាស៊ីស( Moniliasis មើលទំ. ២៤២ )។ ជ្រាំងកើតឡើងជាញឹកញាប់លើទារក លើអ្នកមានផ្ទុកមេរោគអេដស៍ និងលើអ្នកដែលប្រើថ្នាំអង់ទីប៊ីយ៉ូទិកមួយចំនួន ជាពិសេសថ្នាំតេត្រាស៊ីគ្លីន ( Tetracycline ) ឬអំពីស៊ីលីន( Ampicillin )។

ឈប់លេបថ្នាំអង់ទីប៊ីយ៉ូទិក លើកលែងតែក្នុងករណីចាំបាច់បំផុតដែលត្រូវតែបន្ត លេប។ លាបផ្នែកក្នុងនៃមាត់ ដោយហ្សង់ទ្យានវីយូឡេ។ ការទំពារខ្ទឹមស ឬការបរិភោគទឹកដោះគោជូរ ក៏អាចជួយបានដែរ។ ក្នុងករណីធ្ងន់ធ្ងរ ប្រើថ្នាំនីស្តាទីន ( Nystatin ទំ.៣៦៩ )។



**ដំបៅក្នុងមាត់ ៖** ពងតូចៗពណ៌ស ឈឺចាប់ នៅលើបបូរមាត់ ឬក្នុងមាត់។ វាអាចកើតឡើងបន្ទាប់ពីមានគ្រុនក្តៅ ឬមានការព្រួយបារម្ភច្រើន។ ក្នុងរយៈពេលមួយ ទៅបីអាទិត្យ វាជាសះស្បើយទៅវិញដោយឯកឯង។ ខ្ពុរជម្រះមាត់ជាមួយទឹកអំបិល ឬលាយជាមួយអ៊ីដ្រូហ្សែនពេរ៉ុកស៊ីតបន្តិច ឬប្រើក្រមួនកូរទីកូស្តេរ៉ូអ៊ីដ( Corticosteroid ទំ.៣៧១ )។ ថ្នាំអង់ទីប៊ីយ៉ូទិកមិនមានប្រយោជន៍ទេ។

# ដំបៅបបូរមាត់ និងពងក្នុងមាត់ដែលបណ្តាលមកពីគ្រុនក្តៅ

ពងតូចៗដែលមានការឈឺចាប់ នៅលើបបូរមាត់( ឬលើប្រដាប់ភេទ ) ដែលបែកហើយបង្កជាក្រមរ។ អាចកើតឡើងបន្ទាប់ពីមានគ្រុនក្តៅ ឬមានការព្រួយបារម្ភច្រើន។ វាបណ្តាលមកពីវីរុស Herpes។ វាជាសះស្បើយវិញបន្ទាប់ពី១ទៅ២សប្តាហ៍។ ការដាក់ទឹកកកលើពងតូចៗនោះរយៈពេលជាច្រើននាទី ជាច្រើនដងក្នុងមួយថ្ងៃ អាចជួយឲ្យឆាប់ជាសះវិញ។ គេអាចដាក់សាច់ជូរ និងកំហ្វរ ឬទឹករុក្ខជាតិល្វីង នៅលើដំបៅក៏អាចជួយដែរ។ បើអ្នកលេបថ្នាំអាស៊ីខ្លូវ៉ា( acyclovir ) ភ្លាមៗ ពេលពងតូចៗចាប់ផ្តើមកើតឡើង អាចជួយឲ្យឆាប់ជាសះវិញ។ សម្រាប់ព័ត៌មានស្តីអំពីជំងឺពងទឹកនៅលើប្រដាប់បន្តពូជ សូមមើលទំព័រ៤០២។